# ផ្នែក 504 / កូនសិស្សពិការ

## តើផ្នែក 504 ជាអ្វី?

*"គ្មានវិធីណាផ្សេងទៀតដែលមនុស្សពិការដែលមានសិទ្ធិទទួល ... គ្រាន់តែមានភាពពិការនោះ ត្រូវបានរាំងមិនឱ្យចូលរួម រាំងរាំងមិនឱ្យទទួលអត្ថប្រយោជន៍ ឬដាក់ឱ្យទទួលរងនូវការរើសអើង ក្រោមកម្មវិធី ឬសកម្មភាពណាមួយ ដែលទទួលជំនួយហិរញ្ញវត្ថុពីរដ្ឋសហព័ន្ធឡើយ។ "ផ្នែក 504 នៃច្បាប់ស្តារនីតិសម្បទានៃឆ្នាំ 1973។*

ផ្នែក 504 គឺជាច្បាប់សិទ្ធិពលរដ្ឋ។ ដើម្បីបំពេញតាមលក្ខណ:វិនិច្ឆ័យសំរាប់ការការពារពីផ្នែក 504 នោះ កុមារត្រូវ៖

- មានលក្ខណ:អន់ខ្សោយខាងរូបកាយ ឬផ្លូវចិត្ត ដែលធ្វើមានការពិបាកខ្លាំងក្នុងការធ្វើសកម្មភាពចំបងជាប្រចាំ មួយ ឬច្រើនសកម្មភាព។
- មានកំណត់ត្រាបញ្ជាក់អំពីលក្ខណ:អន់ខ្សោយ ឬ
- ត្រូវបានចាត់ទុកថាមានលក្ខណ:អន់ខ្សោយនេះ។

ក្រោមផ្នែក 504 ផែនការមួយអាចត្រូវបានរៀបចំឡើង ដើម្បីជួយកូនសិស្សពិការ ដែលត្រូវការការសម្របសម្រួល ដើម្បីឱ្យគេអាចទទួលបាននូវកម្មវិធីអប់រំទូទៅ។

សូមប្រើតំណភ្ជាប់ខាងក្រោមនេះ ដើម្បីទាញយកកូនសៀវភៅសង្ខេបមួយក្បាលសំរាប់មាតាបិតា ស្តីអំពីគោលនយោបាយនៃផ្នែក 504។

- កូនសៀវភៅ 504 សំរាប់មាតាបិតា ជាភាសាអង់គ្លេស
- កូនសៀវភៅ 504 សំរាប់មាតាបិតា ជាភាសាអេស្ប៉ាញ
- កូនសៀវភៅ 504 សំរាប់មាតាបិតា ជាភាសាចិន
- កូនសៀវភៅ 504 ជាភាសាវៀតណាម
- កូនសៀវភៅ 504 សំរាប់មាតាបិតា ជាភាសាខ្មែរ
- កូនសៀវភៅ 504 ជាភាសាអារ៉ាប់

---

## សំណួរដែលសួរជាញឹកញាប់អំពីផ្នែក 504


1. តើ "សកម្មភាពជាប្រចាំ" ជាអ្វី?
2. តើភាពពិការ ដែលធ្វើឱ្យមានការលំបាកខ្លាំងក្នុងការធ្វើសកម្មភាពចំបងៗជាប្រចាំនោះ មានលក្ខណ:បែបណាខ្លះ?
3. តើនរណាជាអ្នកសម្រេចចិត្ត ប្រសិនបើកូនសិស្សទទួលបំពេញបានទៅតាមលក្ខណ:វិនិច្ឆ័យក្រោមផ្នែក 504 នៃច្បាប់ស្តារនិតិសម្បទានៃឆ្នាំ 1979?
4. តើគំរូនៃការជួយដែលផ្តល់ឱ្យកូនសិស្សនៅក្នុងផែនការ 504 នោះ មានលក្ខណ:បែបណាខ្លះ?
5. តើ មាតាបិតា/អាណាព្យាបាល មានសិទ្ធិអ្វីខ្លះ តាមផ្នែក 504 នៃច្បាប់ស្តារនីតិសម្បទា?
6. តើការប្តឹងតវ៉ាអំពីផ្នែក 504 អាចធ្វើបានរបៀបណា?
7. តើខ្ញុំអាចទទួលបាននូវព័ត៌មាន ឬជំនួយថែមទៀត នៅទីណា?

## តើ "សកម្មភាពជាប្រចាំ" ជាអ្វី?

“សកម្មភាពចំបងជាប្រចាំ” រួមមានដូចជា ការដើរ ការមើល ការស្តាប់ ការនិយាយ ការដកដង្ហើម ការរៀនសូត្រ ការធ្វើកិច្ចការ ការថែខ្លួន និងកិច្ចការហត្ថកម្ម។

## តើភាពពិការ ដែលធ្វើឱ្យមានការមានលំបាកខ្លាំងក្នុងការធ្វើសកម្មភាពចំបងៗជាប្រចាំនោះ មានលក្ខណៈបែបណាខ្លះ?

- ភាពអន់ខ្សោយការប្រុងស្មារតី
- ជម្ងឺមហារីក
- ជម្ងឺហឺតរ៉ាំរ៉ៃ
- ជម្ងឺក្រពេញបញ្ចេញសំណល់ពីខ្លួន (បន្តពីឪពុកម្តាយ)
- ជំងឺទឹកនោមផ្អែម
- ពិការរាងកាយ
- ជំងឺប្រគ្រីវកាច់
- ជម្ងឺទាស់ធ្ងន់ធ្ងរ
- ជំងឺខ្វះកោសិកាឈាមក្រហម
- ពិការភាពបណ្ដោះអាសន្ន

## តើនរណាជាអ្នកសម្រេចចិត្ត ប្រសិនបើកូនសិស្សបំពេញបានទៅតាមលក្ខណ:វិនិច្ឆ័យក្រោមផ្នែក 504 នៃច្បាប់ស្តារនីតិសម្បទានៃឆ្នាំ 1979?

ក្រុមការងារនៃផ្នែក 504 ប្រចាំសាលារៀន នឹងធ្វើការវាយតម្លៃមួយ ដើម្បីកំណត់ថា តើកូនសិស្សបំពេញបានទៅតាមលក្ខណៈវិនិច្ឆ័យ ថាជាមនុស្សពិការ ក្រោមច្បាប់នៃរដ្ឋសហព័ន្ធឬយ៉ាងណា។ ក្រុមនេះនឹងធ្វើការកំណត់ថា តើកូនសិស្សមានលក្ខណ:អន់ខ្សោយខាងរូបកាយ ឬផ្លូវចិត្ត ដែលធ្វើឱ្យមានការពិបាកខ្លាំងក្នុងការធ្វើសកម្មភាពចំបងជាប្រចាំ មួយ ឬច្រើនសកម្មភាព ឬយ៉ាងណា។

## តើគំរូនៃការជួយដែលមានផ្តល់ឱ្យកូនសិស្សនៅក្នុងផែនការ 504 នោះ មានលក្ខណ:បែបណាខ្លះ?

- ឱ្យអង្គុយនៅខាងមុខថ្នាក់រៀន
- បង្កើតផែនការជួយគ្រប់គ្រងអាកប្បកិរិយា
- សម្របសម្រួលក្នុងពេលធ្វើតេស្ត
- ផ្តល់សម្ភារ:សិក្សាតាមទ្រង់ទ្រាយផ្សេងទៀត
- ផ្តល់ពេលវេលាថែមទៀតសំរាប់ធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើនៅផ្ទះ

## តើ មាតាបិតា/អាណាព្យាបាល មានសិទ្ធិអ្វីខ្លះ តាមផ្នែក 504 នៃច្បាប់ស្តារនីតិសម្បទា?

- សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការសម្រេចចិត្តណាមួយ ដែលទាក់ទងនឹងការកំណត់អត្តសញ្ញាណ រង្វាយតម្លៃ និង/ឬ ការសម្របសម្រួល
- ព័ត៌មានដែលត្រូវការចាំបាច់ ដើម្បីស្នើសុំឱ្យធ្វើការសំរេចចិត្តសារជាថ្មីឡើងវិញ ចំពោះកិច្ចសំរេចចិត្តបែបបេះណាមួយ; និង
- ការត្រួតពិនិត្យលើកំណត់ត្រាពាក់ព័ន្ធ

## តើការប្តឹងតវ៉ាអំពីផ្នែក 504 អាចធ្វើបានរបៀបណា?

បណ្តឹងតវ៉ាជាលាយលក្ខណ៍អក្សរអំពីផ្នែក 504 ដែលជាប់ពាក់ពាន់ទៅនឹងចំណុចដូចតទៅនេះ អាចដាក់បានទៅកាន់អ្នកគ្រប់គ្រងសាលារៀន និង/ឬ អ្នកចាត់តាំងនៃផ្នែក 504៖

- ការខ្វែងយោបល់គ្នាចំពោះសេចក្តីសម្រេច ឬវិធានការដែលបានធ្វើ ឬពុំបានធ្វើ ទាក់ទងទៅនឹងវាយតម្លៃ ឬផែនការនៃផ្នែក 504 របស់សិស្ស និង/ឬ
- ការរើសអើង / ការបៀតបៀន ដែលផ្អែកលើភាពពិការពិតប្រាកដ ឬពិការតាមការយល់ឃើញរបស់កូនសិស្ស។

សូមចំណាំថា ពាក្យបណ្តឹងអំពីការរើសអើង ឬការបៀតបៀននោះ ត្រូវតែដាក់ប្តឹងក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃខែដែលហេតុការណ៍ហ្នឹងបានកើតឡើង។ ដំណោះស្រាយគ្នានៅថ្នាក់សាលារៀនតាមមូលដ្ឋាន ត្រូវបានលើកទឹកចិត្តឱ្យធ្វើជាមុនសិន។ ប៉ុន្តែប្រសិនបើពាក្យបណ្តឹងហ្នឹង ពុំអាចដោះស្រាយគ្នាបានទេនោះ ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរមួយច្បាប់ អាចដាក់ដាក់បានទៅកាន់មន្ត្រីសម្របសម្រួលនៃផ្នែក 504។

ប្រសិនបើលោកអ្នកចង់ដាក់ពាក្យបណ្តឹងមួយច្បាប់ នោះលោកអ្នកអាចទាក់ទងមន្ត្រីទទួលពាក្យបណ្តឹងពីប្រជាជនមួយរូប គឺលោក Gabriel Valenzuela ដើម្បីទទួលបាននូវនីតិវិធីបណ្តឹងឯកសណ្ឋានមួយច្បាប់។ ការិយាល័យនៃមន្ត្រីទទួលពាក្យបណ្តឹងពីប្រជាជន គឺមានទីតាំងនៅ 1000 Broadway, Suite 150, Oakland, CA 94607។ ទូរស័ព្ទលេខ (510) 879-3667 ទូរសារលេខ (510) 879-3678 ហើយលោកអ្នកអាចផ្ញើសារជាអេឡិចត្រូនិចទៅមន្ត្រីទទួលពាក្យបណ្តឹងពីប្រជាជន តាមរយៈអ៊ីមែល៖ gabriel.valenzuela@ousd.org។

## តើខ្ញុំអាចទទួលបាននូវព័ត៌មាន ឬជំនួយថែមទៀត នៅទីណា?

សូមស្នើសុំព័ត៌មានថែមទៀត នៅតាមទីសាលារៀនរបស់កូនលោកអ្នក ឬសូមទាក់ទង៖
អ្នកស្រី Barbara Parker អ្នកសម្របសម្រួលផ្នែកបំរើសេវាសុខភាព/ផ្នែក 504 ប្រចាំសង្កាត់
1000 Broadway, Suite 150, Oakland, 94607

អ៊ីមែល៖ 504@ousd.org
(510) 879-2742